ឧបសៅសង្ហា

# កំណាព្យ មនោសញ្ចេតនា




## បទពាក្យ ៧

## ស្នេហាបរិសុទ្ធ

**ស្រី**ឆោមល្អតាំងពីក្រពុំ
ភ័ក្ត្រថ្កុំថ្កើងកើតជាសម្រស់
ព្រែសូត្រជាកាយល្អឥតខ្ចោះ
សាបអស់ចិត្តខ្ញុំជាយុវៈ។

**កាយ**អោយលហុជាវ៉ាយោ
ចរនោររកស្នេហ៍ឃើញរស្មី
ដូចទុំឃើញទារស្ងួនបេតី
មេត្រីទំនៀមត្រូវវន្ទា។

**មិ**នហ៊ានសូមស្នេហ៍ផ្កាផូរផង់
លួចមើលមិនត្រង់ខ្លាចទាវខ្មាស
តែថប់ដង្ហើមចិត្តប្រាលប្រាស
អាសូរពាក្យចាសតបសំនៀង។
**ថា**ផ្កាយល់ច្បាស់ចិត្តបុរស
ចិត្តស្មោះស្រឡាញ់កុលាបពិត
តែផ្កាចូលម្លប់ជាច្បាប់រិទ្ធ
ត្រូវសាងចរិតស្រីគ្រប់លក្ខណ៍។

**យើ**ងនៅក្មេងចិត្តបរិសុទ្ធ
កាយចិត្តពិស្សុតជាឥស្សរៈ
សេរីភាពមានក្នុងលោកៈ
រស្មីអក្កៈ[1]ជួយបំភ្លឺ។
**ផ្លូវ**ត្រូវតាមកេរ្ត៍ពៅពិសី
ពៅស្រីក្រពុំផ្កាមានទង
វង្សាបុត្រីលើបង្កង
ម៉ែឱគាត់គងពៅលើពេជ្រ។
**តែ**ចិត្តកម្លោះជាគុជព្រាន

1 អក្កៈ, ព្រះអាទិត្រ។

ចិត្តចង់បំពានក្បួនសាស្ត្រា
ឃើញនោមស្រីល្អលួចស្នេហា
កុលាបជីវាក្នុងជីវិត។

**លួ**ចចិត្តបរិសុទ្ធផ្កាក្រពុំ
គ្មានសុំកុលាបក្រហមល្អ
ព្រោះធ្លាក់ខ្លួនប្រាណជាទាសក
ស្នេហ៍កុលាបល្អបាត់ស្មារតី។

**ញ**ញឹមៗគ្មានចម្លើយ
តែមិនប្រដើយក្នុងកែវភ្នែក
នាំឲកម្លោះកាន់តែស្រែក
ស្នេហ៍ចង់វែកចិត្តរកការពិត។

**ញ**ញឹមព័ន្ធចិត្តមិនរំដោះ
ក៏មិនបានប្រស់ទុក្ខបុរស
ចិត្តប្រុសចុះចាញ់នោមសម្រស់
ឥតខ្ចោះបំផុសបឋមស្នេហ៍។

**ប្រ**តិព័ន្ធកុលាបជាស្នេហ៍ឯក
ជាស្នេហ៍យុវះចិត្តពិមល
ប្រុសពានេចរលែងរវល់

នរៈសុទន្ត[2]ជាកេរ្តិ៍ច្បាប់។
**ញ**ញ្ញឹមមិនឈប់ជាជម្មជាតិ
ជាធាតុប្ញសជាត៍ស្រីពុំងា
នាំឲថេន[3]ស្នេហ៍ចិត្តកំព្រា
ក្រោបកាយស្នេហានោមបុប្ផា។

**ក្លើ**ចំអកថាប្រុសកំសាក
ចិត្តចង់សិក្ខាក្បួនសាសង
គួសង្សារដូចអូនទឹងបង
ក្នុងបំណងត្រងពាក្យភ្នកស្នេហ៏។
**តែ**ខ្លាចក្រៀមក្រមសណ្តំចិត្ត
អោយរឹតកើតទុក្ខក្នុងឱរា
មិនដឹងថ្លែងអ្វីជាមួយផ្កា
ប្រាថ្នាអឹផងពេលឃើញភក្រ្ត។
**ក្លើ**សើចឃើញប្រុសដង្ហើមភាំង
ភ្លេចភ្លាំងឆ្វេងស្តាំអន្ទះសា
ពេលឃើញបុប្ផាពីចម្ងាយ
ផិតឆ្ងាយលែងដឹងផ្លូវត្រូវដើរ។

---
2 នរៈសុទន្ត, មនុស្សមានការអប់រំល្អ។
3 ថេន, ចោរ។

**ល**ង់លុះចង់ជួបពៅពិសី
តែចិត្តបេតីខ្លាចកុលាប
មិនចោលនេត្រាមកប្រុសថ្កាន
ជាឋានមោទនារួមមោហ:។

**ដើ**រកាន់តែបៀតកុលាបស្រី
ចិត្តមានសេរីស្លុតឱរា
ខ្លួនស្លុរព្រោះរោគសង្ស្សា
រាគត្បាតឆាប់រ៉ារាងកាយប្រុស។
**គឺ**រោគស្នេហាផ្តួចគ្នានក្សាន្ត
ជិតឆ្ងាយដូងផ្កាភ័យខុសគ្នា
នៅក្បែរព្រួយខ្លាចស្រីពុំងា
រេរាមិនប្តូរប្រស្រ័យភ្នែក។
**ព្រួ**យស្ទើរដង្ហើមផុតម្ចាស់ចិត្ត
ស្រីគិតថាប្រុសគ្នានទំនង
ដើរតាមបុប្ផាជាអ្នកគ្រង
កុលាបមួយទងដួងចិត្តសែត។
**ពិ**លាសីស្ងួនបាញ់ដូចព្រួញ
គំនក់ទំនួញចិត្តហាមឈាន
ជើងប្រុសទុរពលលែងហ៊ាន

បោះមួយជំហានដើរទៅមុខ។

**កា**យស្រីខិតកាន់តែមកជិត
ពំនិតគឺឆ្កោកខ្លួនបុរស
អោយស្លុតជំហរចិត្តនិត្យស្មោះ
ព្រោះចាញ់សម្រស់ឆក់ទាញចិត្ត។
**ស្រ**ឡាញ់អ្វីម្លេះផ្កាក្រពុំ
ពេលនៅទៀបឃុំពាក្យពេចន៍ស្នេហ៍
ភ្នែករំពៃស្ទង់មេឃចង់ប្រែ
ទិសបែររកស្រីថាំងប្រភា។
**ឆ**ដា[4]ស្រីចេញពីឆោមរូប
បន្ទោរន្ទូតជាជម្ពូជាតិ
ក្ដីបផ្កាហើមពេលព្រឹកព្រាង
បក្សីស្រែកច្រៀង៩ក្រពុំ។
**នៅ**ក្បែរស្រីផៀបឈើក្នុងពោះ
ពិតព្រោះចង់ក្បង់ក្លិនភ្ញាស្ងួន
គន្ធក្រអូបន្ទួនពីផ្កាទេព
និវេទន៍ភ្នែកទន់ពភ្លៀកស្រី។

---
4 ឆដា, រស្មី ឬ សម្រស់។

**ច**ង់ស្ដីរកស្រីមានល្អសជាំង
បន្លាររនាំងជារាំសនា
ហាមសាកច្ឆា[5]ចមទ្វិន្ទ[6]សង្សារ
អូនបងភក្សា[7]ជាភក្ដី។
**ចំ**ណីស្នេហាប្រុសនិងស្រី
សំដីដំណូរចិត្តនិងចិត្ត
តែកម្មអ្វីមានពីអតិត
មិនអាចប្រឌិតហួសកំរិត។
**កុ**លាបគ្រាច់ផុតពីមុមភ្នែក
មិនបានរំលែកចិត្តមេត្រី
គ្មានផស្ស[8]អ្វីសោះសទ្ធិន្ទ្រិយ[9]
ជាក្ដីសង្ឃឹមមានខ្លឹមសារ។
**ស្នេ**ហាបរិសុទ្ធនិត្រក្នុងចិត្ត
វាផ្ដិតនៅជាប់ដួងអារម្មណ៍
ទោះញញឹមស្រីគ្មានបារម្ភ
នឹកន្ទួនចង់ដោះរនាំងស្នេហ៍៕

---

5 សាកច្ឆា, សន្ទនា។
6 ទ្វិន្ទ, ជាគូ។
7 ភក្សា, ម្ហូបចំណី។
8 ផស្ស, សញ្ញា។
9 សទ្ធិន្ទ្រិយ, បេះដូងមានមេត្តា។